CAMBODIA EXPRESS NEWS

# ណាត់ជួបយប់ជ្រៅ និង ក្លូស្លុកណា

**និពន្ធដោយ**

**ខូវ ប៊ុន ហាក់**

## ណាត់ជួបពេលយប់ជ្រៅ

រាល់ព្រឹកថ្ងៃអាទិត្យ សូខុន ជាមនុស្សនៅលីវមិនដឹងទៅណា ក៏តែង ដើរកំសាន្តតាមដងវិថី ។

ជួនកាលយប់គយគន់រំពៃរថយន្តថ្មីៗ ដែលគេតាំងក្នុងអាគារកញ្ចក់ ជួនកាលឈរមើលរូបភាពដែលគេផ្សាយតាមរោងភាពយន្ត ។

ព្រឹកថ្ងៃអាទិត្យនេះ អ្នកកំពុងមើលរូបភាព "វាសនាផ្ការំដួល" នៅ រោងកុនអេដែន ស្រាប់តែមានសំឡេងស្ត្រីស្រែកហៅខ្លួន សូខុន ក៏ងាកក្រឡេង ទៅឃើញស្រីម្នាក់រូបឆោមស្រស់ប្រិមប្រិយញញឹមមករក ។

សូខុន ខំនឹកឈ្មោះស្ត្រីនោះ ទើបស្គាល់ថាជា វ៉ាន់ សឿន ដែលធ្លាប់ ជាកំណាន់ចិត្តរបស់ខ្លួន កាលនាងនៅជានាដករនៅ "តាហ៊ិទី"

"ស្អាតម្លេះលោកស្រី មើលសឹងមិនស្គាល់ អញ្ជើញមើលកុនឬ ?"

-"ទេ ទេ ថ្ងៃនេះគ្មានពេលទំនេរទេ "

-"បើឥចឹងញ៉ាំអីបន្តិចសិន"

-"ចាំស មានអីបង"

ដូច្នោះ អ្នកទាំងពីរក៏នាំគ្នាដើចូលទៅភោជនីយដ្ឋានជិតៗនោះ ហើយ ហៅភេសជ្ជៈត្រជាក់មកទទួលទាន ។

ការសាសងមានដូចតទៅ :

-"ស្មានថាគេមានប្ដីលែងស្គាល់ខ្ញុំហើយ "

-កុំមានប្រសាសន៏ឥចឹងបង តាំងពីនោះរហូតមកខ្ញុំមិនដែលភ្លេចបង ទេ ថ្វីត្បិតតែខ្ញុំមានប្ដី បងជ្រាបស្រាប់ហើយ ខ្ញុំយកប្ដីនោះក៏យកដោយគ្រាន់ តែជាបង្គោលប៉ុណ្ណោះទេ ព្រោះប្ដីខ្ញុំចាស់ណាស់ទៅហើយ ។

-ចាស់ស្បែកក្រាស់កម្លាំងមាន ។ ហើយមានប្រាក់ទៀត សូខុន ឆ្លើយ ដោយចំអក

-"មានប្រាក់មិនមែនទិញអ្វីបានទាំងអស់ទេបង" សម្តីមួយម៉ាត់នេះ មានអត្ថន័យជ្រៅណាស់ ប៉ុន្តែ សូខុន នៅតែមិនទាន់អស់ចិត្ត ។

-មែនហើយមានប្រាក់មិនមែនទិញអ្វីបានទាំងអស់ ប៉ុន្តែបើមិនមែន ប្រាក់នេះ រ៉ាន់សឿន អូននាងក៏មិនមែនសុខចិត្តយកប្តីចាស់ដែរមែនទេ ?

-ឱ ! ហេតុតែបងក្រ បានជា ...

-បង ខុន បងនៅតែមិនអាណិតចិត្តខ្ញុំសោះ នាងរ៉ាន់សឿន ថាបណ្តើរ អង្អែលដៃ សូខុន បណ្តើរ ។

-ល្ហើយចុះ វាហួសទៅហើយ កុំនិយាយធ្វើអ្វីទៀតនាំឱ្យស្តាយ ក្រោយ ។

-បង ! បងកុំដាក់ផ្លែផ្កាឱ្យខ្ញុំយ៉ាងនេះទៀត បងដឹងទេខ្ញុំមិនដែល ភ្លេចបងទេ

-ភ្លេចពុំភ្លេចមិនខុសគ្នាប៉ុន្មានទេ អរគុណនាងច្រើន ព្រោះដាក់ចិត្ត ហ៊ានមកញ៉ាំភេសជ្ជៈជាមួយនឹងខ្ញុំ ។

-"ហ៊ឹស " នាង រ៉ាន់ សឿន បួញមាត់ថា យកប្តីមិនមែនលក់ខ្លួនផ្តាច់ ហើយលែងហ៊ានញ៉ាំអ្វីជាមួយប្រុសទេបង ឱភ្លេចប្រាប់បងថា ប្តីខ្ញុំគេទៅ ហុង កុង ពីម្សិលមិញនេះ ។

-"អូ ... អូ ... "

-ចាស ខ្ញុំដឹងចិត្តបងចង់និយាយថា កុំតែប្តីខ្ញុំទៅបាត់ប្រហែលជាមិន ហ៊ានជួបនឹងបងទេ ... មែនឬមិនមែនបង ?

សូខុន នៅស្ងៀមមិនឆ្លើយតប

-"បងខុន កុំខឹងណា បងណា យប់នេះខ្ញុំសុំអញ្ជើញបងទៅផ្ទះខ្ញុំ ខ្ញុំ មានចំណីឆ្ងាញ់ពិសារជូនបងញ៉ាំ ទៅមិនទៅបង បើទៅទៅយប់ហ្នឹង ព្រោះយប់ ស្អែកប្តីខ្ញុំគេត្រឡប់មកពី ហុងកុង វិញហើយ"

-កុំឱ្យ រ៉ាន់សឿន ពិបាកដោយសារបង

-កុំមានប្រសាសន៍ឥចឹងទៀតបង ប៉ុន្តែ "នាង រ៉ាន់សឿន និយាយតិច ៗ "សុំបងម៉ោងមួយយប់ជ្រៅសិមទៅ កុំចុចកណ្តឹងឱ្យសោះ ពីព្រោះខ្ញុំនិងបើក ទ្វាររបងជាស្រេចចាំបង ។

-ម៉េចក៏យប់ម្ល៉េះ ?

-មិនដឹងធ្វើម៉េចទេ កុំឱ្យអ្នកជិតខាងគេដឹង គេតិះដៀលខ្ញុំថា គ្រាន់ តែប្តីទៅបាត់ស្ងាត់ៗហៅប្រុសមកដេកផ្ទះ នេះហើយដែលហៅថា "ណាត់ជួប ពេលយប់ជ្រៅ" ។

-"ណាត់ជួបពេលយប់ជ្រៅ" ស័ព្ទផ្អែមល្ហែមនេះធ្វើឱ្យ សូខុន ស្លាប់ ចិត្តស្លុក ។

-បានកុំភ្លេចចាំបង ផ្ទះមានឆ្កែកាចឬទេ ?

-គ្មានទេបង សុំបងកត់ទីលំនៅខ្ញុំសិនតិចរកច្រឡំផ្ទះ សូខុន ខំកត់ យ៉ាងប្រញាប់ នាង រ៉ាន់ សឿន ក៏លាខ្លួនចេញទៅមុន ។

ថ្ងៃនេះ សូខុន នៅមិនសុខទេក្នុងចិត្តអរៗ សសន់ខំបន់ឱ្យតែព្រះ អាទិត្យអស្តង្គតឱ្យឆាប់ៗ ដើម្បីប្រញាប់រៀបខ្លួនទៅជួបនាង រ៉ាន់ សឿន

លុះដល់ទ្រនិចនាឡិកាចង្អុលម៉ោងមួយយប់ សូខុន ទៅដល់ទីកំណត់ ឥតល្បើង ក្រឡេកមើលទៅឃើញនាង រ៉ាន់ សឿន ឈរនៅរានហាលធ្វើដៃជា សញ្ញាឱ្យចូល ក៏រុញទ្វារចូលភ្លាម ។

ទៅដល់ក្នុងផ្ទះកាលណា សូខុន រកមើលអ្វីក៏មិនឃើញពីព្រោះនាង រ៉ាន់ សឿន មិនហ៊ានបើកចង្កៀង អ្នកក៏សួរថា :

-"ចុះក៏ង ...."

-"ស៊ីស៊ី ស៊ីត ... កុំមាត់ខ្លាំងពេកបង ព្រោះមីឈ្នួលវាដេកនៅ ខាងក្រៅ "

-"ចុះម៉េចក៏មិនបើកចង្កៀង"

-"កុំឱ្យអ្នកជិតខាងគេឃើញ ងងឹតឥចឹងហើយស្រួលបង មកខ្ញុំដឹក ដៃបងដើរតាមខ្ញុំ"

ថាហើយនាង រ៉ាន់ សឿន អូសដៃ សូខុន ដើរទីមទើម១ទៅរកកន្លែង ទទួលភ្ញៀវ សូខុន លែងហ៊ានមាត់ ដើរតាមដូចជាមនុស្សខ្វាក់ ទើបតែលើក ជើងឈាន ស្បែកជើងបាតស្បែកឮសូរប្រិប១ក្នុងរាត្រីស្ងាត់ ធ្វើឱ្យនាង រ៉ាន់ សឿន ទ្រាំពុំបានថា :

-"បង ! ដោះស្បែកជើងចង្រៃនេះចេញទៅ បើមិនដោះមុខជាភ្ញាក់ គេឯងអស់ហើយ"

សូខុន ខំដោះដោយបន្ថើរដៃដាក់នៅក្បែរទ្វារ ហើយដើរទៅរកតុ អង្គុយ អង្គុយរួចក៏រុញជើងទៅមុខ ប៉ះជើងនឹងជើងតុ លាន់សូរម៉ុាំង ចុកស្ទើរ តែភ្លាត់មាត់ស្រែក

"យីបងឯងកុំខ្លាំងពេក"

-"នៅជេរទៀត ឈឺរកកលនឹងស្លាប់ទៅហើយ "

-"កុំខឹងបង ចាំខ្ញុំរឹតឱ្យ"

សូខុន បន្ទន់សំឡេងថា :

-"មិនអីទេ មិនអីទេ!"

-អង្គុយលេងសិន ចាំខ្ញុំយកស្វាយខ្ទិះចិតស្រាប់មកជូនបងញ៉ាំ ។

-អរគុណ !

នាង រ៉ាន់សឿន ដើរទៅដល់មុខទូទឹកកក ហើយត្រឡប់ងាកមកប្រាប់ សូខុន ថា :

-សុំបងក្រោកដើរទៅជ្រុងជញ្ជាំងសិន ព្រោះតែកាលណាខ្ញុំបើកទូ ទឹកកក មុខជាចង្កៀងក្នុងទូនោះចោលពន្លឺមកក្រៅធ្វើឱ្យផ្ទះលោក សារឿន ដែលមានបង្អួចចំមកបង្អួចផ្ទះខ្ញុំគេឃើញមិនខាន ។

បិទបង្អួចទៅខ្លាចគេសង្ស័យ ណ្ហើយចាំខ្ញុំយកស្វាយខ្ទិះរួចសិមបងមក អង្គុយវិញ ។

"បាបាបាន"ឆ្លើយហើយ សូខុន ក៏ងើបដើរទៅតែមិនបានគិតថាខ្លួន មើលមិនទាន់ច្បាស់នៅឡើយ ។

ម៉ឹង! សូខុន ដើរទៅទង្គិចគម្របចង្កៀងជើងក្បែរជញ្ជាំង ភ្នែកអ្នក បែកអំពិលអំពែក ឈឺចុកចាប់ពេញសៀតថ្ងា ។

ក្រោយពីនោះនាង រ៉ាន់ សឿន បានបើកទូទឹកកកយក ស្វាយខ្ទិះ បិទ ទូហើយហៅ សូខុន ថា :

-"បានហើយបង មកវិញចុះ"

-អន្ធភាពងងឹតក៏កើតឡើងវិញ ។

សូខុន ពិតមែនតែជើងឈឺ ភ្នែកបែកអំពិលអំពែក នៅតែត្រដរដើរ មករកតុវិញដដែល ប៉ុន្តែខុសផ្លូវទៅប៉ះនឹងតុតូច ដែលគេដាក់ប្រអប់គោះបារី ដួល ម្នីម្នាក្រោកឡើងលែងហ៊ានដើរតទៅទៀត

នាង រ៉ាន់សឿន ឆាប់១ស្ទុះមកទាញដៃទៅអង្គុយជិតតុវិញ ។

សូខុន ឈឺពេកអត់ទ្រាំពុំបានភ្លាត់មាត់ថា "ផ្ទះអូនឯងដូចជាទីបង្កប់ ទ័ព កន្លែងណាក៏មានគ្រាប់បែក ប៉ះឯកើតទង្គិចលិច បើយ៉ាងនឹងរកឆ្អឹងធ្វើ បុណ្យគ្មានទេ "

-"នែ ... កុំមាត់ចង្រៃពេកបងឯង ញ៉ាំសិនបង"

សូខុន ញ៉ាំបណ្ដើរ យកដៃអង្អែលត្រង់កន្លែងឈឺបណ្ដើរ ។

ស្វាយខ្ទិះឆ្ងាញ់ពិសាមែនធ្វើឱ្យ សូខុន ភ្លេចទាំងឈឺអស់រលីង ។

-ឆ្ងាញ់ទេបង

-ផ្អែមហើយឈ្ងុយទៀត

-ចាំបងញ៉ាំរួច ខ្ញុំទៅយកសង់ខ្យាខ្ទុះមកឱ្យបងញ៉ាំទៀត បងឯងដឹង ទេ ព្រោះតែបងឯង បានជាខ្ញុំដាក់ពងមាន់ច្រើន ដើម្បីឱ្យមានរសជាតិរីតតែ ឆ្ងាញ់ពិសា ប៉ុណ្ណឹងហើយបងនៅតែថាខ្ញុំចិត្តមិនបានទៀត ។

សម្តីផ្អែមល្ហែមនាំឱ្យ សួខុនគិតថា : "មែននាង វ៉ាន់សឿ គ្មានភ្លេចខ្លួន ទេ ដោយសារធ្លាប់កម្សត់ជាមួយគ្នា "

អ្នកទើបតែរៀបនិយាយថ្លែងអំណរគុណ ស្រាប់តែចំណិតស្វាយខ្ចិះ ដែលនៅក្នុងមាត់ រអិលផ្លូចចូលទៅក្នុងបំពង់កភ្លាមធ្វើឱ្យ សួខុន អួល ស្ទះក្អក មិនឈប់ ។

នាង វ៉ាន់សឿន ក្រែងគេឮស្ទុះយកកន្សែងជូតដៃខ្ទប់មាត់ សួខុន មិន ខ្ទប់តែមាត់ខ្ទប់រហូតច្រមុះ ធ្វើឱ្យ សួខុន ខំបម្រះ

-ម៉េចចង់ខ្ទប់សម្លាប់បងឬ ?

-ចាំះ ទេជ្រុលដៃទៅទេ បងកុំខឹងអ្វី ...

នាង វ៉ាន់សឿន ខ្លាច សួខុន ខឹងក៏រត់ទៅកាត់សង់ខ្យាខ្ទុលដាក់ចាន ទាបមកឱ្យញ៉ាំទៀត ។

ទើបតែរៀបលើកស្លាបព្រាដួសសង់ខ្យាញ៉ាំ ស្រាប់តែមានរថយន្តមួយ មកឈប់នៅមុខផ្ទះ លោក សារឿន គេឃើញប្រពន្ធ លោក សារឿន ចុះពី រថយន្តដើរតាំង៦ឡើងជណ្តើរ ហើយបើកចង្កៀងយោងឱ្យភ្លឺចិញ្ចែង ចង្កៀង ចោលពន្លឺតាមបង្អួចមកផ្ទះនាង វ៉ាន់សឿន នាងក៏ម្នីម្នាទាញដៃ សួខុន ឱ្យចូល ក្រោមតុ ។

-"នៅឱ្យស្ងៀមបង ប្រពន្ធលោកសារឿន ទៅតាមប្តីមិនឃើញ ឥឡូវ មកវិញហើយ កុំឱ្យគេឃើញក្រែងគេថា ...."

សួខុន ភ័យខ្លាំងពេក មុជចូលក្រោមតុភ្លាម តែរហ័សពេកប៉ះថ្ងាស នឹងគែមតុឮសូរផាំង កំពង់តែអង្អែលស្រាប់តែនាង វ៉ាន់សឿន បន្ទោលឡើងថា :

-បងឯងអីក៏ក្តុងក្តាំងមិនឈប់សោះយ៉ាងនេះ !

សួខុន នឹកឡើងខឹងឡើងមិនចេញស្តី

កាលបើឃើញប្រពន្ធលោក សារឿន ដើរជិតមកដល់បង្អួច នាង វ៉ាន់ សឿន ក៏ហុចចានសង់ខ្យាមកឱ្យ សួខុន ទទួលទាន

-ញ៉ាំក្រោមតុទៅបងក្រែងបងឃ្លាន

-នែ៎ ... បងមិនមែនឆ្កែទេ ឱ្យបងញ៉ាំនៅក្រោមតុ

-បើអញ្ចឹង មានតែទៅញ៉ាំក្នុងបន្ទប់ដេកខ្ញុំ នាង វ៉ាន់សឿន និយាយ មិនទាន់ផុតពីមាត់ផង ស្រាប់តែប្រពន្ធលោក សារឿន អើតសួរពីផ្ទះគាត់មក ថា :

-វ៉ាន់សឿន នាងមិនទាន់អេងទេ ?

-ចាំះ អ្នកបងនៅ ... ឱ ...អេងទើបភ្ញាក់ ... បែបឃ្លានកំពុងរកអីញ៉ាំ បន្តិច

-ម៉េចក៏មនបើកចង្កៀង ?

-"ពន្លឺចោលមកពីផ្ទះបងគ្រប់គ្រាន់ហើយ " នាង វ៉ាន់សឿន ឆ្លើយ ដោះស្រាយ ។

-"បើនាងមិនទាន់គេងបើកទ្វារឱ្យបងមួយភ្លែត បងមានការចង់ និយាយ " ថាហើយប្រពន្ធលោក សារឿន ចុះពីលើផ្ទះដើរតម្រង់មក

នាង វ៉ាន់សឿន ឮដូច្នេះក៏ញ័រមាត់រន្ទត់ថា :

-បង សួខុន ស្លាប់ហើយជាន់នេះ សុំបងចូលក្នុងទូខោអាវខ្ញុំសិនទំរាំ ប្រពន្ធលោក សារឿន ទៅវិញ ។

មុននឹងបើកទ្វារឱ្យប្រពន្ធលោក សារឿន នាង វ៉ាន់សឿន បិទ ទ្វារទូ យ៉ាងជិត ។

ចូលមកជិតតុឃើញចានសង់ខ្យាពីរ ប្រពន្ធលោកសារឿនឆ្ងល់ក៏សួរ ថា "យី ម៉េចក៏ម្នាក់ឯងញ៉ាំដល់ទៅពីរចាន "?

-ឱ ... ចាំះឃើញអ្នកបងមក ខំចិតដាក់មួយចានទៀតទុកជូនអ្នក បងញ៉ាំចុះអ្នកបងមកពីណាវិញយប់ថ្មើរនេះ ?

-"ទៅរកប្តីបង គេទៅញ៉ាំការក្មួយ ទៅរកស្រាប់តែបាត់ មើលទៅ មុខជាទៅរាំហើយ ដូចនាង

នាងសំណាងបានប្តីចាស់គេចេះថ្នមប្រពន្ធ បងចាស់ ហើយប្តីគេឡើយណាយ" ។

ថាហើយប្រពន្ធលោក សារឿន ស្រក់ទឹកភ្នែកដោយគាត់អាក់អន់ ចិត្តនឹងប្តីគាត់ណាស់ ។

-"អ្នកបងកុំមានប្រសាសន៍តចឹង លោកប្រុសនោះស្លូតទេ កុំខឹងអី ញ៉ាំសង់ខ្យាសិន ។

ប្រពន្ធលោក សារឿន ញ៉ាំបណ្តើរជេរប្តីឱ្យនាង វ៉ាន់សឿន ស្តាប់បណ្តើរ ។



ចំនែកសូខុន នៅក្នុងទូ ណាមួយក្តៅ ណាមួយថប់ បែកញើសស្រាក់ៗ ដោកអស់ខោអាវ ទ្រាំពុំបានលួចបង្ហើបទ្វារទូមើល ឮថាប្រពន្ធ លោក សារឿន ញ៉ាំសង់ខ្យារបស់ខ្លួន ក៏រឹតតែអាក់អន់ចិត្តថែមទៀត ។

កុំតែលោក សារឿន ត្រឡប់មកផ្ទះវិញ ប្រពន្ធលោក សារឿន ពុំព្រម ទៅផ្ទះទេ ។

"ហ៊ូ ហ៊ូ ហ៊ូស ... នាង វ៉ាន់សឿន ធូរចិត្តលត់ចង្កៀងបិទទ្វារក្រៅ ហើយរត់ទៅក្នុងបន្ទប់ បើកទ្វារទូទាញដៃ សូខុន ចេញ សូខុនមុខស្លេកស្លាំង ថ្ងាសបែកញើសប៉ុនៗគ្រាប់ពោត ចេញមកអង្គុយគ្រវីក្បាលដកដង្ហើមធំ ហួត យកកន្សែងដៃមកជូតញើស ហើយបន្លឺថា :

-"នៅតែបន្តិចទៀតមុខជាដាច់ខ្យល់មិនខាន បើថប់អ្វីក៏ថ្ងប់ម្ល៉េះ "

នាង វ៉ាន់សឿន ក៏ខំលួងលោមតិចៗថា :

-"មិនថ្វីទេបង ចាំខ្ញុំសងជំងឺចិត្តបងឱ្យរួច "

សូខុន ធ្វើមុខជូរហើយខំញញឹម ។

"រឹង ១១១១ "កណ្តឹងរោទិ៍លាន់ឮរំពងក្នុងរាត្រីដ៏ស្ងាត់

នាងវ៉ាន់សឿន រត់ទៅអើតមើលហើយរត់មកប្រាប់ សូខុន ថា :

-"ប្អូនស្រីប្តីខ្ញុំគេមកពីសៀមរាប ... សុំបងអាណិតចូលទៅក្នុងទូខោ អាវសិនទៅ"

-"ទេ ទេ ទេ មិនចូលទេ បើចូលម្តងទៀតមុខជាងាប់មិនខាន "

"ឆាប់ៗ បើអញ្ចឹងចូលក្រោមគ្រែខ្ញុំសិន ប៉ុន្តែសុំបងខិតឱ្យជាប់នឹង ជញ្ជាំង សូខុន មិនដឹងធ្វើម៉េចលូនចូលទៅក្រោមគ្រែនាង រ៉ាន់សឿន ក៏ស្ទុះទៅ បើកទ្វារពិចំងាយសួរសំឡេងស្រួយមួយលាន់ឮឡើង ។ "

-"អ្នកអទ្ទឹងមើលផ្លូវខ្ញុំល្មោចហើយ ហេតុនេះបានជាទទួលសំបុត្របង ប្រុសភ្លាម ខ្ញុំម្ទីម្នាទាំងយប់ "ថាហើយប្អូនថ្លៃនាង រ៉ាន់សឿន ដើរចូលមកក្នុង បន្ទប់ដាក់គូថអង្គុយលើគ្រែដែកដើម្បីរៀបរាប់ដំណើរគាត់តទៅទៀត ។

នាង រ៉ាន់សឿន ធ្វើជាអង្គុយស្តាប់ តែក្នុងចិត្តគិតរកកលបណ្តោះ សូខុន ចេញពីផ្ទះ ព្រោះទុកយូរមុខជាបែកការណ៍មិនខាន ។

តួគ្រែដែកទ្រទម្ងន់ប្អូនថ្លៃនាង រ៉ាន់សឿន ក៏ទន់អែនទៅសង្កត់ សូខុន ដែលខំខាំមាត់អត់ធ្មត់មិនហ៊ានស្រែក លំអងធូលីដែលជាប់នៅក្រោមគ្រែទាំង ប៉ុន្មាន លុះដោយអំណាចចលនាផ្ទៀងផ្អងក៏ជ្រុះធ្លាក់ហុយ ពេញលើខ្លួននឹងចូល ភ្នែក សូខុន ដែលកំពុងរងទោសទុក្ខខាងក្រោម ។

ស្អៀបផង ឈឺផង ថប់ផងហើយរមាស់ទៀត ប្រែខ្លួនមិនរួចមិនដឹង ជាគិតយ៉ាងម៉េចឱ្យរួចពីទីអកុសលនេះ សូខុន ខំបន់ឱ្យប្អូនថ្លៃនាង រ៉ាន់សឿន ទៅណាឱ្យបាត់ទៅ ។ បំណន់ក៏បានសម្រេចដូចបំណងមែន ព្រោះប្អូនថ្លៃនាង រ៉ាន់សឿន ងើបយកខោអាវទៅងូតទឹកឯក្រោយ ។

ពេលនោះនាង រ៉ាន់សឿន ឱនមកខ្សឹបៗថា អស់សង្ឃឹមហើយបង សុំ បងកុំអន់ចិត្តចាំលើកក្រោយ ។

សូខុន បាត់មាត់ បាត់ក ខំលូនចេញមកទាំងត្រដរដើរស្ទាបទៅពាក់ ស្បែកជើងចោលនៅក្រោយទ្វារ ហើយដើរបន្ទើរជើងលួចចេញពីរបងផ្ទះនាង រ៉ាន់សឿន ដោយស្ងាត់ស្ងៀម ។

ខ្យល់រំភើយទ្បើបភ្លឺបក់មកម្តង ៗ ធ្វើឱ្យអ្នកស្រឡះមុខមាត់ហាក់ ដូចជាអ្នកទោស ដែលគេទើបនឹងចេញពីទីឃុំឃាំង ។

លុះដើរទៅដល់មហាវិថិ ស្រាប់តែប្រទះនឹងមិត្តកក្រម្នាក់បញ្ឈប់ រថយន្តសួរថា :

-"សូខុន មកពីណាថ្មើរណេះ?"

-"មកពីផ្ទះ ស្រីកំណាន់ចាស់ ។"

-មកឡើងជិះជាមួយខ្ញុំ ព្រោះមើលទៅបែបអស់កម្លាំងណាស់ហើយ មុខស្លាំងដំណើរទ្រេតទ្រោតៗ ខ្លួនស្រីដេញណាស់សំណាងមែន !

សូខុន ឡើងជិះរថយន្តហើយបិទទ្វារ តែរហ័សពេកក្បៀបត្រូវកូនដៃ ឈឺយ៉ាងខ្លាំង ។

អង្អែលដៃបណ្តើរ នឹកបណ្តើរ "សំណាងមែន បើកុំតែរត់រួច កុំអីជាប់ គុក ឬ គេធ្វើទារុណកម្មជាទម្ងន់មិនខានព្រោះលួចប្រពន្ធគេ ។

## ចប់

## កូនអ្នកណា ?

នៅឫស្សីកែវ ក្បែរមាត់ទន្លេមានផ្ទះបណ្តែតលើទឹកមួយមានរាងជ្រុង ជញ្ជាំងឈើ ដំបូលប្រក់សន្លឹកហ្វីប្រូស៊ីម៉ង់ត៍ ។

វេលានោះគេឃើញបុរសកម្លោះមួយនាក់ ស្លៀកខោខ្លីស ពាក់អាវ យឺតរូបក្រពើកំពុងស្រាយខ្សែកាណូតពណ៌ស ដែលចងភ្ជាប់នឹងផ្ទះនោះ ហើយ បញ្ឆេះម៉ាស៊ីនភ្លាម រួចហុចដៃទៅចាប់ដៃនារីមួយនាក់ស្លៀកសំពត់ជជុលខ្លី នឹង ពាក់អាវផ្កាកូឡាបឱ្យលោតចុះក្នុងកាណូត ។

ក្រោមសុវណ្ណរស្មីនៃព្រះអាទិត្យ ដែលហៀបអស្តង្គតអ្នកលេងកំសាន្ត ទាំងពីរនាក់ បើកកាណូតសតូចនោះកាត់ផ្ទៃទន្លេចុះឡើងៗ ។

នៅលើផ្ទះនោះបុរសម្នាក់ទៀតដែលស្ថិតក្នុងមជ្ឈិមវ័យនៅឡើយ ស្លៀកសារុងសូត្រដេកនឡៀលនៅលើគ្រែ ក្បែរស្ត្រីមួយទៀតរាងធាត់ កំពុង បណ្តែងអារម្មណ៍ ជាមួយនឹងសូរស័ព្ទដំទន់ភ្លន "ខ្យល់បោកបក់ " ផ្សាយតាម វិទ្យុជាតិ ។

លើតុជិតគ្រែ គេឃើញមានកែវស្រាពីរស្ទើរតែហួតនឹងកន្ទុយបារី បង្ហុយផ្សែងពេញបន្ទប់ ។

រលកទឹកបន្តិចតូច បន្តិចធំធ្វើឱ្យផ្ទះបណ្តែងលើទឹកទាំងមូលមាន ចលនាផ្សៀងផ្សងៗ ហាក់ដូចជាឆ្លើយនឹងចង្វាក់អ្នកទាំងពីរកំពុងស្វែងរកការ ស្រើបស្រាល ។

ក្រោយពីការត្រេកត្រអាលរួចមក ការសាសងគ្នាក៏បានចាប់ផ្តើមឡើង ដូចតទៅ :

-ខូចណាស់បងឯង នៅតែដដែលគ្មានប្រែសោះ

**សារ៉ាយ** មនុស្សប្រុសមួយណាដូចមួយណា ឱ ភ្លេចសួរ នាងក្រមុំមក ជាមួយនោះឈ្មោះអី ?

លោក ណាយុត និយាយបណ្តើយ មិចភ្នែកបណ្តើរ

-ឈ្មោះ សៅ នួន ម៉េចបងឯង ឃើញថ្មីចង់ចោលចាស់ឬ .?

ថាហើយអ្នក សារ៉ាយ យកដៃក្តិចភ្លៅលោក ណាយុត

-ទេ ... គ្រាន់តែសុំភ្លក្សចំណីថ្មីទេតើ ?

-កុំលោភពេកបង ស៊ីចាស់ដោយចាស់ ស៊ីក្មេងដោយក្មេងទៅល្អជាង ?

នៅពេលដែលរាត្រីនាំអន្ធភាពមកគ្របលើដងទន្លេ សូរចលនាចក្រ មួយលាន់រោទិ៍ពីចម្ងាយព្រមទាំងមានភ្លើងបញ្ចាំងពន្លឺចុះទៅផ្ទះ គឺជាទ្រុង ទ្រាយនៃកាណូតមួយ ដែលកំពុងរំកិលខ្លួនខិតជិតមកដល់ ។

ប្រុស ស្រីទាំងពីរលោតចុះពីកាណូត ហើយដើរកៀកគ្នាទៅក្នុងបន្ទប់ ហើយគេឃើញលោក ណាយុត នាង សារ៉ាយ ដើរចេញមកដោយញញឹមមើល មុខគ្នា ។

ប្រមាណជាកន្លះម៉ោងក្រោយមក លោក ណាយុត ពោលឡើងថា :

-នៃ លលកញីឈ្មោល ល្មមហើយរកញ៉ាំបាយសិន

-បាទ បង

ឆ្លើយឡើង ផាណេន អ្នកកម្លោះ

ក្រោយពីពេលបាយ អ្នកទាំងបួនទំរេតកាយលើកៅអីវែង ស្តាប់ភ្លេង បស្ចិមប្រទេស ជួនកាលលោក ណាយុត ហៅនាង សៅនួន ឡើងរាំម្តង ជួន កាល ផាណេន ហៅអ្នក សារ៉ាយ ឡើងរាំម្តង ។

យប់កាន់តែជ្រៅ ភ្លេងកាន់តែពិរោះនាដករទាំងប្រុស ស្រីរាំស្ទើរតែ លែងតាមចង្វាត់ ក្រោមកម្លាំងភេសជ្ជៈខ្លាំងៗ អាកប្បកិរិយាកាន់តែសេរីចរ ( រវើរវាយ) ។

លុះពេលទៀបភ្លឺ នាង សៅនួន ភ្ញាក់កាលណា នាងឃើញ លោក ណាយុត ដេកជិតខ្លួន ងាកទៅរក ផាណេន ឃើញដេកលក់កើយដៃអ្នក សារ៉ាយ ។

អំណើះពីនោះមកនាង សៅនួន លួចណាត់ជួបលោក ណាយុត ដោយសារប្រាក់ ជួប ផាណេន ដោយសាររូបនាងមិនធ្វើឱ្យប្រុសទាំងពីរសង្ស័យ ថានាងបានទៅជួបនរណាទៀតក្រៅអំពីខ្លួនទេ ។

មិនយូរប៉ុន្មាននាង សៅនួន កាលបើឃើញពោះកាន់តែធំបន្តិចម្តងៗ ក៏កើតមានក្តីបារម្ភនាងគិតហើយគិតទៀតមុននឹងទៅជួបលោក ណាយុត និង ផាណេន ដើម្បីឱ្យបុរសណា មួយទទួលខុសត្រូវអំពីកូននោះ នាងស្មានក្នុងចិត្តថា :

លោក ណាយុត មានប្រពន្ធហើយមានកូនទៀត រករឿងមានតែរក រឿងធ្វើប្រពន្ធចុង ។

-ចុះ ផាណេន វិញអ្នកនៅរៀនចិត្តទន់ប្រហែលព្រមទទួលខ្លួនជា ប្រពន្ធព្រោះអាណិតកូននៅមន្ទីរ ... ក្នុងការិយាល័យលោក ណាយុត នាង សៅនួន ខំរៀបរាប់ថា ប៉ុន្មានពេលនេះនាងចេះតែក្អួតមិនឈប់សោះ ប្រហែល ជាមានកូនក៏មិនដឹង



លោក ណាយុត ស្តាប់បណ្តើរដៃអេះក្បាលបណ្តើរ

-និយាយលែង ឬ និយាយមែន ?

-កុហកលោកបានការអ្វី ? ឥឡូវសុំលោកជួយគិតខ្ញុំផងចុះ

-ក្រែងជាមួយនរណាទេដឹង ?

-ស្បថជូនគ្មាននរណាក្រៅអំពីលោកទេ !

លោក ណាយុត សញ្ជឹងគិតមួយសន្ទុះទើបសម្រេចចិត្តថា :

-"ប្រពន្ធខ្ញុំកាចណាស់ រកទទួលអូនឯងធ្វើជាប្រពន្ធចុងមិនបានទេ"

គ្រាន់តែឮសម្តីប៉ុណ្ណោះ នាង សៅនួន ស្រក់ទឹកភ្នែកតក់តក់

លោក ណាយុត ឆាប់ៗប្រញាប់រត់ទៅបិទទ្វារបន្ទប់ក្រែគេឮ ហើយ អង្វរនាង សៅនួន ថាចាំខ្លួនគិតមើលដើម្បីដោះស្រាយបញ្ហានេះ ។

នៅបន្ទប់ដេក ផាណេន នាង សៅនួន ប្រើមធ្យោបាយថ្មី ដោយចោទ ផាណេន ថាកូនក្នុងពោះនោះជាស្នាដៃរបស់ ផាណេន ។

-"កុំនិយាយលេងខ្មាសគេណាស់ កម្លោះមានកំណាន់ទាល់តែមានកូន"

-និយាយមែន មិនមែននិយាយលេង បើបងមិនលេងខ្ញុំម្តេចក៏មាន កូន

-"ឈប់ៗ កុំខ្លាំងពេក ក្រែងលោកអ្នកជិតខាងគេឮ"

-"នែបង ហ៊ានស៊ីទាល់តែហ៊ានសងកំសាកអ្វីម្ល៉េះ ។"

-"កុំឆ្លើយដាក់ ស្មានថាបងអាមោយ"

-"ព្រោះថាបងមិនមែនអាមោយ បានជាឱ្យបងទទួលខុសត្រូវ"

-"នែ ! នែ ... កុំលែងឱ្យសោះ បងនៅរៀនបើឪពុកម្ដាយបងនៅ បរទេសដឹងមុខជាងាប់ហើយ "

-"បើបងឯងខ្លាចងាប់ ម្ដេចក៏បងឯងសប្បាយភ្លេចខ្លួន !"

-"ព្រោះតែនឹកឃើញខ្លួន បានជានឹកដល់អនាគតរបស់បង"

-"ចុះអនាគតរបស់ខ្ញុំ នឹងរបស់កូនក្នុងពោះ"

ក្នុងចិត្ត ផាណេន គិតថា : មែនអនាគតនាង សៅនួន អាចមិនគិតបាន ចុះកូននោះគិតយ៉ាងម៉េច ?

-ឱ្យនាងរំលូតកូនចោល ដូចជាចិត្តអាក្រក់ពេក ! ...

-ទុកឱ្យនាងសម្រាលកូន ដូចជាទទួលខ្លួនជាឪពុកកូននោះ សម្រេច ទៅថាជាប្ដីរបស់នាង សៅនួន ហើយមិនតែប៉ុណ្ណោះបានលុយពីណាមកចិញ្ចឹម កូននោះនឹងម៉ែវា



លុយ ពាក្យនេះធ្វើឱ្យ ផាណេន នឹកដល់ការណ៍មួយ អើមែនតាំងអំពី ខ្លួនធ្លាប់ស្នេហ៍ស្និទ្ធជាមួយនាង សៅនួន មកដូចជាមិនដែលឮនាងទារលុយ ចាយសោះ ដូច្នេះមានតែនរណាឱ្យលុយនាងចាយ ។

តែឱ្យចាយមានអ្វីតបស្នង មានតែខ្លួន !

ខ្លួន ខ្លួន យើងក៏ពាល់ គេឱ្យពាល់ សម្រេចទៅនរណាជាអ្នករចនាកូន នោះ ។

គិតហើយ ផាណេន ក៏លួងលោមនាង សៅនួន ថា អ្នកសុំគិតសិនមុន នឹងឆ្លើយសម្រេចអំពីរឿងនេះ ។

ទឹកមុខនាង សៅនួន ក្លាយជាញញឹមហើយស្ទុះមកឱប ផាណេន

ដើម្បីដោះស្រាយបញ្ហាស្មុគ្រស្មាញនេះ ផាណេន ក៏រត់ទៅជួប លោក ណាយុត ពីព្រោះថា :

-ទី ១ លោក ណាយុត ស្គាល់អ្នក សារ៉ាយ មេអណ្ដើក នោះ

-ទី ២ លោក ណាយុត មានការពិសោធន៍ជាងខ្លួន ។

-"បង មានការមួយពឹងបងជួយ"

-"ផាណេន ឯងមានការអ្វីធំ ឬ តូច"

-"ថាធំក៏បានថាតូចក៏បាន"

-"និយាយទៅមើលឱ្យបងស្តាប់ផង"

-"ខ្ញុំបានបំផើមស្ត្រីម្នាក់ ឥឡូវនេះវាមកសុំឱ្យទទួលវាធ្វើប្រពន្ធ"

លោក ណាយុត គិតស្មានក្នុងចិត្តថា (ស្មានតែឯងទេឱ្យស្ត្រីតោង ឥឡូវនេះ ផាណេន ក៏ដែរ) ហើយសួរថា "ចុះផាណេន ឯងគិតយ៉ាងម៉េច"

"វាចាញ់ចំណេះហើយបានមកសួរបង អ្នកមានការពិសោធន៍"

"ស្ត្រីនោះជាស្ត្រីខូច ឬ មួយក៏ស្ត្រីជា ! "

-"ស្ត្រីខូចបង!"

-"បើខូចក្រែងវាខូចនឹងគេឆ្លើយដាក់ ណេន ឯង ! "

-"មិនមែនទេបង វាខូចមែនតែរឿងកូននោះច្បាស់ជាខ្ញុំហើយ" ប៉ុន្តែ ឆ្ងល់ត្រង់ណេះបន្តិច វាមិនដែលទារលុយពីខ្ញុំចាយសោះ តាំងតែពីនោះមកខ្ញុំ គិតថា ...

-"ណេន លាក់បាំងអ្វីបងក៏មានស្ត្រីចោទដែរ"

-"ចុះបងគិតដូចម្តេច ! ឱ្យខ្ញុំតាមបងផង"

-"និយាយទៅស្មុគស្មាញណាស់ មើលទៅដោះមិនរួចទេ "

លោក ណាយុត និង ផាណេន ឈប់សន្ទនាគ្នា ហើយអង្គុយស្ងៀម មើលមុខគ្នា ...

មួយសន្ទុះក្រោយមក លោក ណាយុត និយាយថា :

-"រឿងបងមើលទៅទាល់តែរកអ្នក សារ៉ាយ ជួយបានកើត!!"

ផាណេន ភ្ញាក់ស្មុះលោតឡើងថា ... "ចុះបងទៅរកអ្នក សារ៉ាយ ធ្វើ អ្វីវិញ បើខ្ញុំប្រហែលមែន "

-"អ្នក សារ៉ាយ ព្រោះស្ត្រីនោះ ណេន ឯងចាំឬទេដែលយើងយកទៅ កំសាន្ត នៅផ្ទះបណ្តែតទឹក នៅឫស្សីកែវនោះ"

-"សៅនួន មែនឬមិនមែន? "

-"ហ្នឹងហើយ ! ណេន ឯងរកអ្នក សារ៉ាយ មានការអ្វីដែរ"

( បាទ រឿងនាង សៅនួន នេះដែរ ... )

ក្រោយអំពីប្តូរយោបល់នេះ បុរសទាំងពីរទើបភ្ញាក់ខ្លួនដឹងថា ខ្លួនត្រូវ នាង សៅនួន បំភាន់ហើយគិតរកល្បិចកលយ៉ាងណាឱ្យនាងឆ្លើយដាក់នរណា មិនកើត ។

នៅផ្ទះបណ្តែងលើទឹកឯឫស្សីកែវ លោក ណាយុត ធ្វើជាហៅ នាង សៅនួន ទៅជួបហើយបញ្ឆោតឱ្យនាងឆ្លើយអំពីរឿងកូននោះ ទឹកភ្នែកហូរហាម តាមផ្ទាល់នាង សៅនួន នៅតែរំអុកឱ្យលោក ណាយុត ទទួលខុសត្រូវ ។

ពេលនោះគេឃើញទ្វារបន្ទប់ នោះរបើកហើយ ផាណេន ដើរចេញមក ដោយមានកាន់ប្រដាប់ថតសំឡេងនៅដៃ

ទឹកមុខនាង សៅនួន ប្រែមួយរំពេច ចង់សើចបន្តិចចង់យំបន្តិច ស្ទើរ អៀន ស្ទើរខឹង សម្លឹងមើលមុខលោក ណាយុត ម្តង មើល ផាណេន ម្តង ។

លោក ណាយុត ញញឹមបណ្តើរ ស្ទាបអង្អែលខ្នងនាង សៅនួន បណ្តើរ ... "ម៉េចនាងអស់ចិត្តហើយឬនៅ ? ដេញទាន់គេជាន់កែង កុំអន់ចិត្តធ្វើអ្វី ផាណេន គ្នានៅរៀនចំណែកបងប្រពន្ធកាចណាស់ទទួលធ្វើប្រពន្ធចុងក៏មិនកើត ឈ្លើយគិតដូច្នេះទៅចុះ អំពីរឿងកូននោះ ... លែងទៅរក ផាណេន ទុកឱ្យគ្នា រៀនដើម្បីប្រឡងនៅពេលខាងមុខនេះ "

ចំណែកនាង ខ្ញុំចេញឱ្យនាងមួយខែបីពាន់រៀលរហូតដល់នាង សម្រាលកូន ។

ដល់បានកូនខ្ញុំចេញថ្លៃឱ្យមេដោះ ថែរក្សាកូននោះទៀត ។

ពេលនោះ ផាណេន ឆ្លើយឡើងថា "បងទុកឱ្យខ្ញុំចេញថ្លៃទឹកដោះហ្គ៍ ហួសផង កុំឱ្យបាត់សេចក្ដីសាមគ្គីក្នុងសហប្រតិបត្តិការជាមួយគ្នា"

ក្រោយពីទទួលលុយពីលោក ណាយុត នាង សៅនួន ឱនមុខជ្រុម ដើរចេញពីផ្ទះនោះទៅដោយគ្មានងាកក្រោយ ។

ជាអវសាន ផាណេន សួរបញ្ជាក់លោក ណាយុត ថា :

-"រាល់ថ្ងៃបងជួប សៅនួន ពេលថ្មើរណា បើប្រពន្ធបងតាមជាប់ម្លេះ "

-"ជួបពេលថ្ងៃរសៀល បងភូតប្រពន្ធបងថានៅការិយាល័យបងមាន ការច្រើនណាស់"

-"ចុះ ណេន ឯងជួប សៅនួន ថ្មើរណាដែរ ? ជួបយប់ៗគ្មានលោះមួយ យប់ណាទេ"

-"ឱ ! ឥចឹង បានជាបោកយើងទាំងពីរជិតបាន"

ថាតែប៉ុណ្ណោះ បុរសទាំងពីរនាំគ្នាសើចក្អាកក្អាយ ។

**ចប់**